**Alert.seattle.gov/boilwater** (ការជូនដំណឹង.seattle.រដ្ឋាភិបាល/ទឹកដាំ)

**ការណ៍ពិត ៖** សេវាបម្រើបម្រាស់សាធារណៈ Seattle [Seattle Public Utilities (SPU)] បានចេញសេចក្តីណែនាំអំពីទឹកដាំ នៅតំបន់នានា ក្នុង Seattle ។ ប្រជាពលរដ្ឋ នៅក្នុងតំបន់ដែលរងផលប៉ះពាល់ ត្រូវបានប្រាប់ឱ្យដាំទឹករបស់ពួកគេ មុនពេលយកមកប្រើប្រាស់ ដើម្បីជៀសវាងកុំឱ្យមានជំងឺ និងបញ្ហាសុខភាពផ្សេងៗ ទៀត ។ សេចក្តីណែនាំ នឹងនៅមានសុពលភាព រហូតដល់ពេលលទ្ធផលចេញពីប្រព័ន្ធទឹកនៅតំបន់ដែលរងផលប៉ះពាល់ បញ្ជាក់ថា ទឹកមានសុវត្ថិភាពអាចឱ្យទទួលទានបានហើយ ។

**<u>អ្វីដែលត្រូវធ្វើ</u> ៖**

**កំឡុងពេលមានសេចក្តីណែនាំអំពីទឹកដាំ ៖**

- កុំទទួលទានទឹកតាមរ៉ូប៊ីណេ ដែលមិនទាន់បានសម្លាប់មេរោគ ។ កុំប្រើទឹកកក ឬទទួលទានភេសជ្ជៈ ដែលប្រើទឹកតាមរ៉ូប៊ីណេ ដែលមិនទាន់បានសម្លាប់មេរោគ ឬទទួលទានអាហារឆៅដែលលាងដោយទឹកតាមរ៉ូប៊ីណេ ដែលមិនទាន់បានសម្លាប់មេរោគ ។
- ដើម្បីសម្លាប់មេរោគ ៖ ដាំទឹករយៈពេល មួយនាទី ។ នៅពេលទឹកចុះត្រជាក់ ដាក់ទឹកក្លាសេនៅក្នុងទូរទឹកកក ដោយមានប្រដាប់ផ្ទុកបិទជិត ។
- ទឹកច្រកដបបិទជិត មានសុវត្ថិភាព អាចទទួលទានបាន ។ វាក៏មានសុវត្ថិភាពផងដែរ ក្នុងការប្រើទឹកតាមរ៉ូប៊ីណេធម្មតា សម្រាប់ងូតជម្រះកាយ និងបោកគក់សម្លៀកបំពាក់ ។ កុំឱ្យទារក ឬក្មេងតូចៗ ផឹកទឹកសម្រាប់ងូត ឬជញ្ជក់សម្លៀកបំពាក់បោករួច ។
- ស្តាប់វិទ្យុ មើលទូរទស្សន៍ និងចូលមើលគេហទំព័រ SPU ដើម្បីទទួលបានបច្ចុប្បន្នភាពពីព័ត៌មានស្តីពីគ្រោះអាសន្ន និងដើម្បីឱ្យដឹងពីពេលដែលសេចក្តីណែនាំត្រូវបានដកចេញហើយទឹកមានសុវត្ថិភាព អាចទទួលទានបាន ។
- ***ប្រសិនបើលោកអ្នកស្គាល់បុគ្គលដែលមិនអាច យល់ មើលឃើញ ឬដឹងឮអំពីសារនេះបានទេសូមជួយប្រាប់ពួកគេផង ។***

**ក្រោយពេលសេចក្តីណែនាំអំពីទឹកដាំ ត្រូវបានដកចេញ ៖**

- បង្ហូរទឹកលាងជម្រះបំពង់ទីប និងក្បាលរ៉ូប៊ីណេក្នុងផ្ទះ ៖ បើកក្បាលរ៉ូប៊ីណេបង្ហូរទឹកត្រជាក់ចោល ក្នុងរយៈពេល 3 នាទី សម្រាប់ក្បាលរ៉ូប៊ីណេមួយ ប្រសិនបើក្បាលរ៉ូប៊ីណេនោះ មិនត្រូវបានប្រើប្រាស់ ក្នុងរយៈពេល 24 ម៉ោងមុន ។
- បង្ហូរទឹកលាងជម្រះម៉ាស៊ីនធ្វើទឹកកក ដោយស្វ័យប្រវត្តិ នៅក្នុងផ្ទះ ៖ បើកធ្វើដុំទឹកកកចំនួនបីសារ ហើយបោះដុំទឹកកក ទាំងបីសារ នោះចោលទាំងអស់ ។
- បង្ហូរទឹកចោល ពីម៉ាស៊ីនកំដៅទឹក ហើយបំពេញទឹកមកវិញ ប្រសិនបើសីតុណ្ហភាព មានកំណត់ក្រោម 113 F ។
- បង្ហូរទឹកលាងម៉ាស៊ីនបន្សុទ្ធ (water softeners) ដោយបង្ហូរទឹក តាមវដ្តជំរុញទឹកបំពេញឡើងវិញ (regeneration cycle) ។
- បង្ហូរទឹកលាងជម្រះប្រភពទឹកផឹក ៖ បើកបង្ហូរទឹកចោល ក្នុងរយៈពេល 3 នាទី ។
- បង្ហូរទឹកលាងម៉ាស៊ីនធ្វើឱ្យទឹកត្រជាក់ (water coolers) ៖ បើកបង្ហូរទឹកចោលដោយមាននៅភ្ជាប់ ចរន្តទឹកចូលផ្ទាល់ ក្នុងរយៈពេល 5 នាទី ។

**តំណរបណ្តាញដែលមានប្រយោជន៍ ៖**

http://www.seattle.gov/util/

http://www.kingcounty.gov/healthservices/health/preparedness/disaster/BoilOrder.aspx

http://www.cdc.gov/parasites/crypto/health_professionals/bwa/public.html